# ប្រកាសស្តីពី
# នីតិវិធី បែបបទ និងលក្ខខណ្ឌនៃ
# ការផ្តល់ ផ្ទេរ និងបន្តសុពលភាព
# អាជ្ញាបណ្ណកាស៊ីណូ និង
# ល្បែងផ្សងសំណាង

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ | Scan QR Code

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
លេខ:......០០៤.........គ.ល.ក.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ និងអាជ្ញាបណ្ណល្បែងផ្សងសំណាង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៦៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ដើមទុនអប្បបរមាសម្រាប់ប្រតិបត្តិការកាស៊ីណូ
- យោងតាមការសម្រេចរបស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជានាសម័យប្រជុំលើកទី២ អាណត្តិទី១ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្ដល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ និងអាជ្ញាបណ្ណល្បែងផ្សងសំណាង ព្រមទាំងកាតព្វកិច្ចផ្សេងៗរបស់អ្នកកាន់កាប់អាជ្ញាបណ្ណ ក្នុងគោលដៅធានាបាននូវការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្ដាប់ធ្នាប់ និងរបៀបរៀបរយ នៃរាល់ប្រតិបត្តិការកាស៊ីណូ និងល្បែងផ្សងសំណាង។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះប្រតិបត្តិការមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ប្រតិបត្តិការកាស៊ីណូ និងប្រតិបត្តិការល្បែងផ្សងសំណាង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្ដល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ

**ប្រការ៣.-**

អាជ្ញាបណ្ណកាស៊ីណូត្រូវបានកំណត់ជាបីប្រភេទរួមមាន អាជ្ញាបណ្ណកាស៊ីណូស្ថិតនៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ អាជ្ញាបណ្ណកាស៊ីណូមិនស្ថិតនៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ និងអាជ្ញាបណ្ណកាស៊ីណូដែលមានមុនប្រកាសនេះចូលជាធរមាន។

**ប្រការ៤.-**

នីតិបុគ្គលអាចប្រតិបត្តិការល្បែងកាស៊ីណូបាន លុះត្រាតែមានអាជ្ញាបណ្ណជាមុនពី គ.ល.ក.។

ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូត្រូវអនុលោមតាមមាត្រា២៥ មាត្រា៣០ និងមាត្រា៣៧ នៃច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

**ប្រការ៥.-**

អាជ្ញាបណ្ណកាស៊ីណូស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ មានសុពលភាពមិនលើសពី ២០ (ម្ភៃ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយអាជ្ញាបណ្ណកាស៊ីណូជាសាធារណៈ។

អាជ្ញាបណ្ណកាស៊ីណូមិនស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ មានសុពលភាពមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយអាជ្ញាបណ្ណកាស៊ីណូជាសាធារណៈ។

ក្នុងករណីស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ ប្រតិបត្តិករកាស៊ីណូត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ គ.ល.ក. ក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ មុនពេលផុតសុពលភាព។

**ប្រការ៦.-**

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ ត្រូវមានដើមទុនអប្បបរមាស្របតាមបញ្ញត្តិនៃមាត្រា៤ នៃអនុក្រឹត្យស្ដីពីការកំណត់ដើមទុនអប្បបរមាសម្រាប់ប្រតិបត្តិការកាស៊ីណូ។

ប្រតិបត្តិករកាស៊ីណូ ត្រូវមានមូលធនសុទ្ធអប្បបរមា ១០ (ដប់) ភាគរយ នៃដើមទុន និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ៥ (ប្រាំ) ភាគរយ នៃដើមទុន នៅក្នុងគណនីរបស់ គ.ល.ក.។



ហ៊ុ ២

**ប្រការ៧ ._**

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូ ត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

១. ជាក្រុមហ៊ុនដែលបង្កើត និងចុះបញ្ជីពាណិជ្ជកម្មនិងចុះបញ្ជីពន្ធដារ ស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុន ដែលមានកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ចដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ

២. មានធនធានគ្រប់គ្រាន់ដូចជា ហិរញ្ញវត្ថុ និងធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍តាមមុខតំណែងនីមួយៗនៅក្នុងក្រុមហ៊ុន

៣. មានហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ ដើម្បីផ្តល់សេវាជាប្រតិបត្តិករកាស៊ីណូ និងប្រព័ន្ធទ្រទ្រង់ (Backup System) ដើម្បីធានាបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព

៤. មានទីតាំង និងបំពាក់បរិក្ខារគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការកាស៊ីណូ

៥. មានប្រព័ន្ធ និងគោលនយោបាយគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង

៦. មានយន្តការត្រួតពិនិត្យធុរកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការកាស៊ីណូ

៧. មានវិធាន និងយន្តការត្រួតពិនិត្យនិងដោះស្រាយទំនាស់ផលប្រយោជន៍ដែលអាចកើតមាននៅក្នុងក្រុមហ៊ុន និងការបំពេញកាតព្វកិច្ចតាមច្បាប់។

**ប្រការ៨ ._**

ពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូត្រូវដាក់ជូនអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយភ្ជាប់នូវឯកសារដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លក្ខន្តិកៈក្រុមហ៊ុន និងប័ណ្ណប៉ាតង់ ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

២. កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណ

៣. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃការតែងតាំងបុគ្គលដែលមានគុណវុឌ្ឍិជានាយកប្រតិបត្តិ ឬនាយកគ្រប់គ្រងក្រុមហ៊ុន

៤. បញ្ជីរាយនាមភាគហ៊ុនិកដោយបញ្ជាក់ពីចំនួនភាគហ៊ុន និងបញ្ជីរាយនាមអភិបាល និងបញ្ជីរាយនាមបុគ្គលិកពិសេស ដោយបញ្ជាក់ពីតួនាទីនិងបទពិសោធន៍ការងារ ភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃ ព្រមទាំងលិខិតបញ្ជាក់ទោសច្បាប់ដើម

៥. គោលការណ៍អភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ពីនាយករដ្ឋមន្ត្រី សម្រាប់កាស៊ីណូស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬគោលការណ៍អភិវឌ្ឍន៍កាស៊ីណូពីនាយករដ្ឋមន្ត្រី សម្រាប់កាស៊ីណូមិនស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍

៦. កិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូរវាងប្រតិបត្តិករកាស៊ីណូ និងកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូ សម្រាប់កាស៊ីណូស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកិច្ចព្រមព្រៀងប្រតិបត្តិការកាស៊ីណូរវាងប្រតិបត្តិករកាស៊ីណូ និងកម្មសិទ្ធិករកាស៊ីណូ សម្រាប់កាស៊ីណូមិនស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍

៧. កិច្ចសន្យាជួលទីតាំង ឬប័ណ្ណកម្មសិទ្ធិ ថតចម្លងដោយមានការបញ្ជាក់ពីសារការី
៨. ប្លង់បរិវេណកាស៊ីណូ និងទីតាំងរៀបចំឧបករណ៍ល្បែង
៩. បញ្ជីរាយឧបករណ៍ និង/ឬកម្មវិធីល្បែង
១០. ឯកសារស្តីពីវិធានល្បែង របៀបលេង និងនីតិវិធីទូទាត់សំណង
១១. ឯកសារបញ្ជាក់ពីដើមទុន (ដូចមានកំណត់ក្នុងមាត្រា៤ នៃអនុក្រឹត្យស្តីពីការកំណត់ដើមទុនអប្បបរមាសម្រាប់ប្រតិបត្តិការកាស៊ីណូ) និងឯកសារបញ្ជាក់ធនធានហិរញ្ញវត្ថុឬមានលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ គ្រប់គ្រាន់សម្រាប់ធានានិរន្តរភាពហិរញ្ញវត្ថុនិងធានានូវដំណើរការនិងការគ្រប់គ្រងកាស៊ីណូ
១២. ឯកសារបញ្ជាក់អំពីប្រាក់តម្កល់ធានាអាជីវកម្ម
១៣. ផែនការស្តីពីការគ្រប់គ្រងធនធានមនុស្ស ដោយបង្ហាញពីចំនួនបុគ្គលិកដែលក្រុមហ៊ុនត្រូវមាន (បុគ្គលិកខ្មែរនិងបរទេស)និងគោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស
១៤. ឯកសារស្តីពីការសិក្សាសមិទ្ធិលទ្ធភាព និងផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំ ខាងមុខ
១៥. គោលការណ៍អភិបាលកិច្ចក្រុមហ៊ុនរួមមាន ការត្រួតពិនិត្យផ្ទៃក្នុង គណនេយ្យ សវនកម្មរបស់ក្រុមហ៊ុន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ
១៦. គោលការណ៍ប្រតិបត្តិស្តង់ដានៃផ្នែកនីមួយៗរបស់ក្រុមហ៊ុន
១៧. គោលការណ៍ណែនាំស្តីពីនីតិវិធីទប់ស្កាត់បុគ្គលត្រូវហាមឃាត់ អនុលោមតាមមាត្រា៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
១៨. គោលការណ៍ត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
១៩. រចនាសម្ព័ន្ធនៃសម្ព័ន្ធក្រុមហ៊ុន ក្រុមហ៊ុនមេ និងចំនួនបុគ្គលិក (ប្រសិនបើមាន)
២០. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចក្នុងរយៈពេល ៣ (បី) ឆ្នាំកន្លងមក (សម្រាប់សម្ព័ន្ធក្រុមហ៊ុន)។

**ប្រការ៩ .-**

ពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូត្រូវស្នើឡើងដោយប្រធានក្រុមប្រឹក្សាភិបាល ឬបុគ្គលទទួលបានសិទ្ធិពីក្រុមប្រឹក្សាភិបាល ដែលអាចជាអភិបាល ឬនាយកប្រតិបត្តិនៃមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍។

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវផ្តល់ជូនអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. នូវព័ត៌មានដូចខាងក្រោម៖

១. ប្រវត្តិរូប ដោយត្រូវមានបញ្ជាក់ពីកម្រិតវប្បធម៌និងបទពិសោធន៍ និងភ្ជាប់រូបថត ៤ x ៦ ចំនួន ៣ (បី) សន្លឹក
២. លិខិតថ្កោលទោស ច្បាប់ដើម
៣. កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណ
៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ
៥. សៀវភៅការងារ (សម្រាប់ជនបរទេស) ត្រូវផ្តល់ក្នុងរយៈពេល ៣ (បី) ខែបន្ទាប់ពីទទួលបានអាជ្ញាបណ្ណ។

**ប្រការ១០ .-**

អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវធ្វើការសិក្សា ស្រាវជ្រាវ និងពិចារណាលើពាក្យស្នើសុំ ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូ។ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណកាស៊ីណូផ្តល់ឯកសារបន្ថែម និងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ១១ ៖**

គ.ល.ក. មានសិទ្ធិយល់ព្រម ឬបដិសេធលើពាក្យស្នើសុំ។ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. មានភារកិច្ចជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្ដីសម្រេចយល់ព្រម ឬបដិសេធផ្ដល់អាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ១២ ៖**

កម្មសិទ្ធិករកាស៊ីណូ ដែលមានបំណងផ្ទេរអាជ្ញាបណ្ណកាស៊ីណូទៅឱ្យភាគីណាមួយ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយត្រូវបំពេញនូវលក្ខខណ្ឌ ដូចខាងក្រោម៖

១. ផ្ដល់លក្ខន្តិកៈក្រុមហ៊ុន (ជាភាសាខ្មែរ) ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

២. ផ្ដល់ប្រវត្តិរូបរបស់អ្នកដែលត្រូវផ្ទេរ ដោយភ្ជាប់ លិខិតថ្កោលទោសច្បាប់ដើម អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លង ដោយមានបញ្ជាក់ត្រឹមត្រូវ និងរូបថត ៤ x ៦ ចំនួន ៣ (បី) សន្លឹក

៣. បង់កម្រៃផ្ទេរអាជ្ញាបណ្ណចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល និងកម្រៃសម្រាប់ចំណាយរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ ស៊ើបអង្កេត ឬជួលជំនាញការ ជាដើម ដែលចាំបាច់ត្រូវធ្វើឡើងក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំផ្ទេរអាជ្ញាបណ្ណចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដោយត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក.

៤. ផ្ដល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃការផ្ទេរអាជ្ញាបណ្ណកាស៊ីណូ

៥. ផ្ដល់ឯកសារប្រគល់សិទ្ធិ ឬឯកសារបញ្ជាក់ការយល់ព្រមពាក់ព័ន្ធចាំបាច់ ដើម្បីឱ្យអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. អាចធ្វើការស្រាវជ្រាវនិងសាកសួរ ឬដើម្បីទទួលបានព័ត៌មាន និងឯកសារពាក់ព័ន្ធ

៦. ផ្ដល់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមទៅអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ប្រសិនមានការផ្លាស់ប្ដូរកើតឡើងពាក់ព័ន្ធនឹងព័ត៌មាន និងឯកសារ។

**ប្រការ១៣ ៖**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់កម្រៃទម្រង់ការ សម្រាប់ការស្នើសុំអាជ្ញាបណ្ណកាស៊ីណូស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ចំនួន ៤.០០០.០០០ (បួនលាន) រៀល ក្នុងមួយច្បាប់។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ប្រាក់សម្រាប់ចំណាយរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងការសិក្សាស្រាវជ្រាវ ស៊ើបអង្កេត ឬជួលជំនាញការ ជាដើម ដែលចាំបាច់ត្រូវធ្វើឡើងក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំនោះ តាំងពីចាប់ផ្ដើមរហូតដល់ចប់ ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល។

**ប្រការ១៤ ៖**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់កម្រៃទម្រង់ការ សម្រាប់ការស្នើសុំអាជ្ញាបណ្ណកាស៊ីណូមិនស្ថិតក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ចំនួន ២.០០០.០០០ (ពីរលាន) រៀល ក្នុងមួយច្បាប់។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ប្រាក់សម្រាប់ចំណាយរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងការសិក្សាស្រាវជ្រាវ ស៊ើបអង្កេត ឬជួលជំនាញការ ជាដើម ដែលចាំបាច់ត្រូវធ្វើឡើងក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំនោះ តាំងពីចាប់ផ្ដើមរហូតដល់ចប់ ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល។

**ប្រការ១៥ -**

ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវបង់កម្រៃអាជ្ញាបណ្ណកាស៊ីណូប្រចាំឆ្នាំ ចំនួន ៤០០.០០០.០០០ (បួនរយលាន) រៀល។

ចំពោះកាស៊ីណូដែលមានអាជ្ញាបណ្ណមុនប្រកាសនេះចូលជាធរមាន ត្រូវចាត់ទុកជាប្រភេទអនុគ្រោះ ដោយត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំជា ៥ (ប្រាំ) ដំណាក់កាល ដូចខាងក្រោម៖

- ដំណាក់កាលទី១៖ ពីឆ្នាំទី១ ដល់ឆ្នាំទី៣ ត្រូវបង់ចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល
- ដំណាក់កាលទី២៖ ពីឆ្នាំទី៤ ដល់ឆ្នាំទី៦ ត្រូវបង់ចំនួន ២៤០.០០០.០០០ (ពីររយសែសិបលាន) រៀល
- ដំណាក់កាលទី៣៖ ពីឆ្នាំទី៧ ដល់ឆ្នាំទី៩ ត្រូវបង់ចំនួន ២៨០.០០០.០០០ (ពីររយប៉ែតសិបលាន) រៀល
- ដំណាក់កាលទី៤៖ ពីឆ្នាំទី១០ ដល់ឆ្នាំទី១២ ត្រូវបង់ចំនួន ៣២០.០០០.០០០ (បីរយម្ភៃលាន) រៀល
- ដំណាក់កាលទី៥៖ ពីឆ្នាំទី១៣ ដល់ឆ្នាំទី១៥ ត្រូវបង់ចំនួន ៣៦០.០០០.០០០ (បីរយហុកសិបលាន) រៀល។

**ប្រការ១៦ -**

ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ ចូលទៅក្នុងគណនីរបស់ គ.ល.ក. ដោយមិនលើសពីថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

**ប្រការ១៧ -**

រាល់ការផ្ទេរភាគហ៊ុនរបស់ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ភាគីផ្ទេរភាគហ៊ុនត្រូវបង់កម្រៃចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល និងត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក.។

**ប្រការ១៨ -**

រាល់ការបង្កើន ឬបន្ថយដើមទុនរបស់ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ភាគីបង្កើនឬបន្ថយដើមទុនត្រូវបង់កម្រៃ ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល និងត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក.។

## ជំពូកទី៣

## នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ និងការបន្តសុពលភាព អាជ្ញាបណ្ណល្បែងផ្សងសំណាង និងអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង

**ប្រការ១៩ -**

ល្បែងផ្សងសំណាងអាចដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែមានអាជ្ញាបណ្ណជាមុនពី គ.ល.ក.។

មានតែនីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទេទើបអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាងបាន។

អាជ្ញាបណ្ណល្បែងផ្សងសំណាងមានសុពលភាពមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

ក្នុងករណីស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ប្រតិបត្តិករល្បែងផ្សងសំណាងត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ គ.ល.ក. ក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ មុនពេលផុតសុពលភាពនៃអាជ្ញាបណ្ណ។

**ប្រការ២០ ._**

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តសុពលភាពអាជ្ញាបណ្ណធ្វើប្រតិបត្តិការល្បែងផ្សងសំណាង ត្រូវមានដើមទុនអប្បបរមា ចាប់ពី ២០.០០០.០០០.០០០ (ម្ភៃប៊ីលាន) រៀល ឡើងទៅ។

ដើមទុនសម្រាប់ប្រតិបត្តិករល្បែងផ្សងសំណាង សំដៅដល់ទ្រព្យសកម្មចរន្ត រួមទាំងមូលនិធិរបស់ភាគហ៊ុនិកនៅក្នុងក្រុមហ៊ុន និងអចលនទ្រព្យរបស់ក្រុមហ៊ុននោះ ដោយដកចេញនូវ៖

- ទ្រព្យសកម្មមិនមែនចរន្ត និងចំណាយដែលបានបង់មុនរបស់ក្រុមហ៊ុន
- ឥណទានដែលគ្មានការធានា និងប្រាក់បុរេប្រទានដែលផ្តល់ដោយក្រុមហ៊ុន ហើយដែលត្រូវបានចាត់ទុកជាទ្រព្យសកម្មចរន្ត
- ចំនួនទឹកប្រាក់ដែលត្រូវបង់ដោយអភិបាល សហកម្មសិទ្ធិករ ឬសមាការីទៅឱ្យក្រុមហ៊ុន ហើយដែលត្រូវបានចាត់ទុកជាទ្រព្យសកម្មចរន្ត
- តម្លៃលើសពីតម្លៃមូលបត្រ ដែលបានកត់ត្រាទុកបញ្ជី ដែលកាន់ទុកក្នុងគណនីផ្ទាល់របស់ក្រុមហ៊ុនទៅតាមតម្លៃទីផ្សារ
- ឱនភាពគណនីអតិថិជន ដោយដកចេញនូវសំវិធានធនបំណុលទារមិនបាន ឬពិបាកទារ ហើយរៀបចំក្នុងទម្រង់មួយទៅតាមការកំណត់របស់ គ.ល.ក.។

សមាសធាតុផ្សេងទៀតក្នុងការគណនាមូលធនសុទ្ធរបស់ក្រុមហ៊ុន ត្រូវកំណត់ក្នុងប្រកាសដោយឡែករបស់ គ.ល.ក.។

ប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវមានមូលធនសុទ្ធអប្បបរមា ១០ (ដប់) ភាគរយ នៃដើមទុន និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយ នៃដើមទុន នៅក្នុងគណនីរបស់ គ.ល.ក.។

**ប្រការ២១ ._**

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាងត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

១. ជាក្រុមហ៊ុនដែលបង្កើត និងចុះបញ្ជីពាណិជ្ជកម្មនិងចុះបញ្ជីពន្ធដារស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនដែលមានកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ចដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ

២. មានធនធានគ្រប់គ្រាន់ដូចជា ហិរញ្ញវត្ថុ និងធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍តាមមុខតំណែងនីមួយៗនៅក្នុងក្រុមហ៊ុន

៣. មានហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ ដើម្បីផ្តល់សេវាជាប្រតិបត្តិករល្បែងផ្សងសំណាង និងប្រព័ន្ធទ្រទ្រង់ (Backup System) ដើម្បីធានាបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព

៤. មានទីតាំង និងបំពាក់បរិក្ខារគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការល្បែងផ្សងសំណាង
៥. មានប្រព័ន្ធ និងគោលនយោបាយគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង
៦. មានយន្តការត្រួតពិនិត្យធុរកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការល្បែងផ្សងសំណាង
៧. មានវិធាន និងយន្តការត្រួតពិនិត្យនិងដោះស្រាយទំនាស់ផលប្រយោជន៍ដែលអាចកើតមាននៅក្នុងក្រុមហ៊ុន និងការបំពេញកាតព្វកិច្ចតាមច្បាប់។

**ប្រការ២២ _**

ពាក្យស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាង ត្រូវដាក់ជូនអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយភ្ជាប់នូវឯកសារ ដូចខាងក្រោម៖

១. វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លក្ខន្តិកៈក្រុមហ៊ុន និងប័ណ្ណប៉ាតង់ ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ
២. កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណ
៣. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃការតែងតាំងបុគ្គលដែលមានគុណវុឌ្ឍិជានាយកប្រតិបត្តិ ឬនាយកគ្រប់គ្រងក្រុមហ៊ុន
៤. បញ្ជីរាយនាមភាគហ៊ុនិកដោយបញ្ជាក់ពីចំនួនភាគហ៊ុន និងបញ្ជីរាយនាមអភិបាល ដោយបញ្ជាក់ពីតួនាទីនិងបទពិសោធន៍ការងារ ភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ថតចម្លង ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃ ព្រមទាំងលិខិតថ្កោលទោសច្បាប់ដើម
៥. កិច្ចសន្យាជួលទីតាំង ឬប័ណ្ណកម្មសិទ្ធិ ថតចម្លងដោយមានការបញ្ជាក់ពីសារការី
៦. ឯកសារស្តីពីឧបករណ៍ល្បែងផ្សងសំណាង វិធានល្បែង របៀបលេង និងនីតិវិធីទូទាត់រង្វាន់
៧. ឯកសារបញ្ជាក់ពីដើមទុន និងឯកសារបញ្ជាក់ធនធានហិរញ្ញវត្ថុឬមានលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ គ្រប់គ្រាន់សម្រាប់ធានានិរន្តរភាពហិរញ្ញវត្ថុនិងធានានូវដំណើរការ និងការគ្រប់គ្រងល្បែងផ្សងសំណាង
៨. ឯកសារបញ្ជាក់អំពីប្រាក់តម្កល់ធានាអាជីវកម្ម
៩. ផែនការស្តីពីការគ្រប់គ្រងធនធានមនុស្ស ដោយបង្ហាញពីចំនួនបុគ្គលិកដែលក្រុមហ៊ុនត្រូវមាន (បុគ្គលិកខ្មែរនិងបរទេស)និងគោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស
១០. ឯកសារស្តីពីការសិក្សាសមិទ្ធិលទ្ធភាព និងផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំខាងមុខ
១១. គោលការណ៍អភិបាលកិច្ចក្រុមហ៊ុនរួមមាន ការត្រួតពិនិត្យផ្ទៃក្នុង គណនេយ្យ សវនកម្មរបស់ក្រុមហ៊ុន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ
១២. គោលការណ៍ប្រតិបត្តិស្តង់ដានៃផ្នែកនីមួយៗរបស់ក្រុមហ៊ុន
១៣. គោលការណ៍ទីផ្សារ និងផ្សព្វផ្សាយពាណិជ្ជកម្ម
១៤. គោលការណ៍ត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
១៥. ផែនការរៀបចំ និងគ្រប់គ្រងសន្តិសុខនិងសណ្តាប់ធ្នាប់
១៦. រចនាសម្ព័ន្ធនៃសម្ព័ន្ធក្រុមហ៊ុន ក្រុមហ៊ុនមេ និងចំនួនបុគ្គលិក (ប្រសិនបើមាន)
១៧. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចក្នុងរយៈពេល ៣ (បី) ឆ្នាំកន្លងមក (សម្រាប់សម្ព័ន្ធក្រុមហ៊ុន)។

**ប្រការ២៣ ‗**

ពាក្យស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាង ត្រូវស្នើឡើងដោយប្រធានក្រុមប្រឹក្សាភិបាល ឬបុគ្គលទទួលបានសិទ្ធិពីក្រុមប្រឹក្សាភិបាល ដែលអាចជាអភិបាល ឬនាយកប្រតិបត្តិរបស់ក្រុមហ៊ុន។

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាង ត្រូវផ្តល់ជូនអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. នូវព័ត៌មានដូចខាងក្រោម៖

១. ប្រវត្តិរូប ដោយត្រូវមានបញ្ជាក់ពីកម្រិតវប្បធម៌និងបទពិសោធន៍ និងភ្ជាប់រូបថត ៤ x ៦ ចំនួន ៣ (បី) សន្លឹក

២. លិខិតថ្កោលទោស ច្បាប់ដើម

៣. កំណត់ហេតុប្រជុំភាគហ៊ុនិក ឬស្ថាបនិក ឬក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណ

៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

៥. សៀវភៅការងារ (សម្រាប់ជនបរទេស) ត្រូវផ្តល់ក្នុងរយៈពេល ៣ (បី) ខែបន្ទាប់ពីទទួលបានអាជ្ញាបណ្ណ។

**ប្រការ២៤ ‗**

បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាង អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវ៖

១. ធ្វើការសិក្សា ស្រាវជ្រាវ និងសាកសួរ តាមការចាំបាច់

២. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មាន ឬឯកសារពាក់ព័ន្ធបន្ថែមតាមការចាំបាច់

៣. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ឯកសារប្រគល់សិទ្ធិ ឬឯកសារបញ្ជាក់ការយល់ព្រមពាក់ព័ន្ធចាំបាច់ដើម្បីឱ្យអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. អាចធ្វើការស្រាវជ្រាវនិងសាកសួរ ឬដើម្បីទទួលបានព័ត៌មាន និងឯកសារពាក់ព័ន្ធ

៤. តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ភស្តុតាងចាំបាច់នានា

៥. ជួលជំនាញការ ឬទីប្រឹក្សាសម្រាប់វាយតម្លៃលើពាក្យស្នើសុំដែលចំណាយនេះជាបន្ទុករបស់អ្នកដាក់ពាក្យស្នើសុំ។

ប្រសិនមានការផ្លាស់ប្តូរកើតឡើងពាក់ព័ន្ធនឹងព័ត៌មាន និងឯកសារដែលទាមទារដោយអគ្គលេខាធិការ-ដ្ឋាននៃ គ.ល.ក. ឬពាក់ព័ន្ធនឹងផ្នែកសំខាន់ណាមួយនៃពាក្យស្នើសុំ នៅមុនពេលដែលពាក្យស្នើសុំត្រូវបានទទួល ឬបដិសេធ អ្នកដាក់ពាក្យស្នើសុំត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមទៅអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. អំពីការផ្លាស់ប្តូរនោះ។

ក្នុងអំឡុងពេលដែលពាក្យស្នើសុំកំពុងដំណើរការ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. អាចផ្តល់អនុសាសន៍ដល់អ្នកដាក់ពាក្យស្នើសុំឱ្យកែប្រែខ្លឹមសារសំខាន់ៗមួយចំនួនចំពោះពាក្យស្នើសុំរបស់ខ្លួន ហើយអ្នកដាក់ពាក្យស្នើសុំនឹងត្រូវបានផ្តល់ឱកាសឱ្យមានយោបល់លើអនុសាសន៍នោះ។

ប្រសិនអ្នកដាក់ពាក្យស្នើសុំដកពាក្យស្នើសុំរបស់ខ្លួនវិញ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. មានសិទ្ធិរក្សាទុកនូវសោហ៊ុយទម្រង់ការទាំងអស់។ ក្នុងករណីនេះ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវផ្ទេរទៅឱ្យអ្នកដាក់ពាក្យស្នើសុំនូវចំនួនទឹកប្រាក់ដែលបានតម្កល់និងមិនទាន់ប្រើប្រាស់ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

សេចក្តីបញ្ជាក់របស់ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. អំពីចំណាយលើការសិក្សាស្រាវជ្រាវរបស់ខ្លួន គឺជាភស្តុតាងគ្រប់គ្រាន់សម្រាប់ប្រភេទចំណាយនេះ ដែលជាបន្ទុករបស់អ្នកដាក់ពាក្យស្នើសុំ។

ពាក្យស្នើសុំព័ត៌មាន និងឯកសារពាក់ព័ន្ធទាំងអស់ ដែលផ្តល់ជូនអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ ហើយព័ត៌មាន និងឯកសារទាំងនេះមិនត្រូវបានបើកចំហចំពោះបុគ្គលណាមួយក្រៅពីអ្នកដាក់ពាក្យស្នើសុំ តំណាងស្របច្បាប់ ឬមេធាវីរបស់អ្នកដាក់ពាក្យស្នើសុំឡើយ លើកលែងតែអ្នកដាក់ពាក្យស្នើសុំ ឬអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. បានកំណត់ដោយឡែក។

**ប្រការ២៥ _**

គ.ល.ក. មានសិទ្ធិយល់ព្រម ឬបដិសេធលើពាក្យស្នើសុំ។

អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. មានភារកិច្ចជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចយល់ព្រម ឬបដិសេធផ្តល់អាជ្ញាប័ណ្ណ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ ពេញលេញ។

**ប្រការ២៦ _**

ប្រតិបត្តិករល្បែងផ្សងសំណាង អាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណសម្រាប់បើកសាខាបាន ដោយត្រូវស្នើឡើងដោយប្រធានក្រុមប្រឹក្សាភិបាល ឬបុគ្គលទទួលបានសិទ្ធិពីក្រុមប្រឹក្សាភិបាល ដែលអាចជាអភិបាល ឬនាយកប្រតិបត្តិរបស់ក្រុមហ៊ុន។

ប្រតិបត្តិករល្បែងផ្សងសំណាង អាចចាត់តាំងបុគ្គលណាម្នាក់ឱ្យឈរឈ្មោះក្នុងអាជ្ញាប័ណ្ណសាខាបានតែមួយប៉ុណ្ណោះ ទោះបីបុគ្គលនោះមានឈ្មោះ ឬគ្មានឈ្មោះនៅក្នុងលក្ខន្តិកៈក្រុមហ៊ុនក៏ដោយ។ ប្រតិបត្តិករល្បែងផ្សងសំណាងត្រូវតែងតាំងបុគ្គលឈរឈ្មោះនោះ ជាប្រធាន ឬនាយកសាខា។

អាជ្ញាប័ណ្ណសាខាមួយ អាចដំណើរការបានសម្រាប់តែមួយសាខាប៉ុណ្ណោះ។

អាជ្ញាប័ណ្ណសាខាមានសុពលភាពមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាប័ណ្ណសាខា ឬស្របតាមសុពលភាពនៃអាជ្ញាប័ណ្ណល្បែងផ្សងសំណាង។ ក្នុងករណីស្នើសុំបន្តសុពលភាពអាជ្ញាប័ណ្ណសាខាប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយ គ.ល.ក. ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ខែ មុនពេលផុតសុពលភាពនៃអាជ្ញាប័ណ្ណសាខានោះ។

**ប្រការ២៧ _**

ពាក្យស្នើសុំអាជ្ញាប័ណ្ណសម្រាប់បើកសាខាល្បែងផ្សងសំណាង ត្រូវដាក់ជូនអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយភ្ជាប់នូវឯកសារ ដូចខាងក្រោម៖

១. អាជ្ញាប័ណ្ណល្បែងផ្សងសំណាងថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

២. លិខិតចាត់តាំងពីប្រតិបត្តិករល្បែងផ្សងសំណាងសម្រាប់អ្នកឈរឈ្មោះអាជ្ញាប័ណ្ណសាខា

៣. លិខិតតែងតាំងនាយក/ប្រធានសាខាថ្មី

៤. លិខិតថ្កោលទោសច្បាប់ដើមរបស់អ្នកឈរឈ្មោះអាជ្ញាប័ណ្ណសាខា

៥. ប្រវត្តិរូប ដោយត្រូវមានបញ្ជាក់នូវកម្រិតវប្បធម៌និងបទពិសោធន៍ របស់អ្នកឈរឈ្មោះក្នុងអាជ្ញាប័ណ្ណសាខា និងភ្ជាប់រូបថត ៤ x ៦ ចំនួន ៣ (បី) សន្លឹក

៦. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ របស់អ្នកឈរឈ្មោះក្នុងអាជ្ញាប័ណ្ណសាខា

៧. កិច្ចសន្យាជួលទីតាំង ឬប័ណ្ណកម្មសិទ្ធិ ថតចម្លងដោយមានការបញ្ជាក់ពីសារការី

**ប្រការ៣០.-**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ប្រាក់សម្រាប់ចំណាយរបស់ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ ស៊ើប-អង្កេត ឬជួលជំនាញការ ជាដើម ដែលចាំបាច់ត្រូវធ្វើឡើងក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំនោះ តាំងពីចាប់ផ្ដើមរហូតដល់ចប់ ដូចខាងក្រោម៖

១. ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល សម្រាប់ការស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាង

២. ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់ការស្នើសុំអាជ្ញាបណ្ណសាខាល្បែងផ្សង-សំណាង។

**ប្រការ៣១.-**

ប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល។ ក្នុងករណីប្រតិបត្តិករល្បែងផ្សងសំណាងមានបំណងបន្ថែមប្រភេទល្បែងផ្សងសំណាង ត្រូវដាក់ពាក្យស្នើសុំមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. និងបង់កម្រៃចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុង ១ (មួយ) ប្រភេទល្បែង។

ប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវបង់កម្រៃអាជ្ញាបណ្ណសាខាប្រចាំឆ្នាំចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងមួយសាខា ឬមួយទីតាំង។

ប្រតិបត្តិករល្បែងផ្សងសំណាង អាចបើកប៉ុស្តិ៍សេវាជាតំណាងរបស់ប្រតិបត្តិករល្បែងផ្សងសំណាងដែលទទួលបានការអនុញ្ញាតពី គ.ល.ក. ដោយត្រូវបង់កម្រៃប្រចាំឆ្នាំ ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុងមួយប៉ុស្តិ៍សេវា។

**ប្រការ៣២.-**

ប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវបង់កម្រៃអាជ្ញាបណ្ណ ឬកម្រៃអាជ្ញាបណ្ណសាខាប្រចាំឆ្នាំ ចូលទៅក្នុងគណនីរបស់ គ.ល.ក. ដោយមិនលើសពីថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

**ប្រការ៣៣.-**

រាល់ការផ្ទេរភាគហ៊ុនរបស់ប្រតិបត្តិករល្បែងផ្សងសំណាង ភាគីផ្ទេរភាគហ៊ុនត្រូវបង់កម្រៃចំនួន ២០០.០០០.០០០ (ពីររយលាន) រៀល និងត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក.។

**ប្រការ៣៤.-**

រាល់ការបង្កើន ឬបន្ថយដើមទុនរបស់ប្រតិបត្តិករល្បែងផ្សងសំណាង ភាគីបង្កើន ឬបន្ថយដើមទុនត្រូវបង់កម្រៃចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល និងត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក.។

## ជំពូកទី៤
## កាតព្វកិច្ចផ្សេងៗ

**ប្រការ៣៥.-**

ប្រតិបត្តិករកាស៊ីណូដែលមានអាជ្ញាបណ្ណកាស៊ីណូ ត្រូវចាប់ផ្ដើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយអាជ្ញាបណ្ណជាសាធារណៈ។ ប្រតិបត្តិករកាស៊ីណូ ត្រូវបើក ផ្អាក ឬបិទដំណើរការកាស៊ីណូ ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

ប្រតិបត្តិករល្បែងផ្សងសំណាងដែលមានអាជ្ញាបណ្ណល្បែងផ្សងសំណាង ត្រូវចាប់ផ្ដើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ ហើយប្រតិបត្តិករល្បែង

៨. ឯកសារបញ្ជាក់ពីសិទ្ធិប្រើប្រាស់ទីតាំង ឬបរិវេណសាខា ពីអាជ្ញាធរដែនដី

៩. រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាខាថ្មី

១០. របាយការណ៍សិក្សាអំពីសក្តានុពលនៃសាខាថ្មី

១១. ផែនការអាជីវកម្មរយៈពេល ៣ (បី) ឆ្នាំ សម្រាប់សាខាថ្មី។

**ប្រការ២៨.-**

កម្មសិទ្ធិករល្បែងផ្សងសំណាង ដែលមានបំណងផ្ទេរអាជ្ញាបណ្ណ និង/ឬអាជ្ញាបណ្ណសាខា ទៅឱ្យភាគីណាមួយ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

១. ផ្តល់លក្ខន្តិកៈក្រុមហ៊ុន (ជាភាសាខ្មែរ) ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

២. ផ្តល់ប្រវត្តិរូបរបស់អ្នកដែលត្រូវផ្ទេរ ដោយភ្ជាប់មកនូវសញ្ញាបត្រ និង/ឬវិញ្ញាបនបត្រជំនាញ លិខិតបញ្ជាក់ទោសច្បាប់ដើម អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនថតចម្លង និងរូបថត ៤ x ៦ ចំនួន ៣ (បី) សន្លឹក

៣. បង់កម្រៃផ្ទេរអាជ្ញាបណ្ណចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល និងកម្រៃសម្រាប់ចំណាយរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ ស៊ើបអង្កេត ឬជួលជំនាញការជាដើម ដែលចាំបាច់ត្រូវធ្វើឡើងក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំផ្ទេរអាជ្ញាបណ្ណចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដោយត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក.

៤. បង់កម្រៃផ្ទេរអាជ្ញាបណ្ណសាខាចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល និងកម្រៃសម្រាប់ចំណាយរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងដំណើរការវាយតម្លៃលើពាក្យស្នើសុំផ្ទេរអាជ្ញាបណ្ណសាខា ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក.

៥. ផ្តល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃការផ្ទេរអាជ្ញាបណ្ណ ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង

៦. ផ្តល់ឯកសារប្រគល់សិទ្ធិ ឬឯកសារបញ្ជាក់ការយល់ព្រមពាក់ព័ន្ធចាំបាច់ ដើម្បីឱ្យអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. អាចធ្វើការស្រាវជ្រាវនិងសាកសួរ ឬដើម្បីទទួលបានព័ត៌មាន និងឯកសារពាក់ព័ន្ធ

៧. ផ្តល់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមទៅអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ប្រសិនមានការផ្លាស់ប្តូរកើតឡើងពាក់ព័ន្ធនឹងព័ត៌មាន និងឯកសារ។

**ប្រការ២៩ .-**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់កម្រៃទម្រង់ការ សម្រាប់ការស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាង និងអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង ដូចខាងក្រោម៖

១. ចំនួន ៤.០០០.០០០ (បួនលាន) រៀល ក្នុងមួយច្បាប់ សម្រាប់ការស្នើសុំអាជ្ញាបណ្ណល្បែងផ្សងសំណាង

២. ចំនួន ២.០០០.០០០ (ពីរលាន) រៀល ក្នុងមួយច្បាប់ សម្រាប់ការស្នើសុំអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង។

ផ្សងសំណាងដែលមានអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាង ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណសាខា។ ក្នុងករណីប្រតិបត្តិករល្បែងផ្សងសំណាងផ្អាក ឬបិទដំណើរការជាបណ្តោះអាសន្ន ត្រូវមានការអនុញ្ញាតជាមុនពីអគ្គលេខាធិការ គ.ល.ក.។

**ប្រការ៣៦ .-**

កម្មសិទ្ធិករ អភិបាល នាយកប្រតិបត្តិ ឬបុគ្គលិករបស់ប្រតិបត្តិករកាស៊ីណូ និងប្រតិបត្តិករល្បែងផ្សងសំណាងដែលទទួលបានអាជ្ញាបណ្ណ ត្រូវចូលរួមវគ្គបណ្តុះបណ្តាលនានាដែលរៀបចំដោយអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី គ.ល.ក. លើកលែងតែមានការកំណត់ដោយឡែកតាមស្ថានភាពជាក់ស្តែង ដោយអគ្គលេខាធិការ គ.ល.ក.។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**ប្រការ៣៧ .-**

បុគ្គលណាដែលធ្វើប្រតិបត្តិការកាស៊ីណូ ឬតាំងខ្លួនធ្វើជាប្រតិបត្តិករកាស៊ីណូ ធ្វើប្រតិបត្តិការល្បែងផ្សងសំណាង ឬតាំងខ្លួនធ្វើជាប្រតិបត្តិករល្បែងផ្សងសំណាង ដោយគ្មានអាជ្ញាបណ្ណកាស៊ីណូ អាជ្ញាបណ្ណល្បែងផ្សងសំណាង ឬអាជ្ញាបណ្ណសាខាល្បែងផ្សងសំណាងពី គ.ល.ក. ត្រូវផ្តន្ទាទោសតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៣៨ .-**

ប្រតិបត្តិករកាស៊ីណូនិង/ឬកម្មសិទ្ធិករកាស៊ីណូ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ និងប្រតិបត្តិករល្បែងផ្សងសំណាង ដែលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌណាមួយដែលចែងដោយអនុលោមតាមប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**ប្រការ៣៩ .-**

ប្រតិបត្តិករកាស៊ីណូ និងប្រតិបត្តិករល្បែងផ្សងសំណាង ដែលមានអាជ្ញាបណ្ណមុនប្រកាសនេះចូលជាធរមាន និងមានបំណងបន្តប្រតិបត្តិការអាជីវកម្ម ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណទៅតាមទម្រង់និងបែបបទដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនផុតសុពលភាពអាជ្ញាបណ្ណ។ ក្នុងរយៈពេលនៃការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណនេះ ប្រតិបត្តិករកាស៊ីណូ និងប្រតិបត្តិករល្បែងផ្សងសំណាង អាចបន្តធ្វើប្រតិបត្តិការអាជីវកម្មបាន រហូតដល់មានការសម្រេចយល់ព្រម ឬបដិសេធលើពាក្យស្នើសុំពី គ.ល.ក.។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ៤០ .-**

អគ្គលេខាធិការ គ.ល.ក. អាចចេញសេចក្តីណែនាំ អនុលោមតាមច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

**ប្រការ៤១ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤២ ._**

អគ្គលេខាធិការ គ.ល.ក. អគ្គលេខាធិការរង គ.ល.ក. ប្រធាននាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សមាសភាពនៃ គ.ល.ក.
- រដ្ឋបាលរាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ